# ហាម ចាប់ សម្លាប់

របបនៅភ្នំពេញ ប្រឈមមុខនឹងស្ថានការណ៍[1]បីយ៉ាង : ឬក៏ ហាមមិនឱ្យ សម រង្ស៊ី ជាពលរដ្ឋខ្មែរម្នាក់ វិលត្រឡប់ចូលស្រុកខ្មែរ ឬក៏ ចាប់ ទណ្ឌិតនេះ ដាក់ពន្ធនាគារ ឬក៏ សម្លាប់ អ្នកប្រឆាំងនយោបាយនេះតែម្តង។ ស្ថានការណ៍នីមួយៗ សុទ្ធតែបង្កើត នូវបញ្ហាបនយោបាយបន្ថែមដល់ខ្លួន ដែលរបបនេះកំពុងជួបប្រទះរួចហើយគឺ ភាពមិនស្របច្បាប់របស់ខ្លួន នៅចំពោះមុខ ប្រជាពលរដ្ឋខ្មែរ និង មតិសហគមន៍អន្តរជាតិ ព្រោះការបោះឆ្នោតនៅឆ្នាំ ២០១៣ គេទុកជាការបោះឆ្នោតក្លែងក្លាយ, ចាប់ កឹម សុខា ដាក់ពន្ធនាគារ និង រំលាយចោលគណបក្សប្រឆាំងចម្បង មិនឱ្យចូលរួមបោះឆ្នោត។ ហើយនៅក្នុងបរិបទ ដែលនឹងអាចទទួលទណ្ឌកម្មពី សហភាពអឺរ៉ុប, សហរដ្ឋអាមេរិក និង អង្គការសហប្រជាជាតិ, របបនៅភ្នំពេញជ្រើសយក ការហាមឃាត់ រង្ស៊ី មិនឱ្យចូលស្រុក ដោយយល់ឃើញថា វាមានភាពអាក្រក់តិចជាង ព្រោះជារបៀបមិនប្រើកម្លាំងហិង្សាទៅលើរូបកាយនរៈនេះ។ តែបំរាមនេះ វាជាអំពើហិង្សាមួយដែរ ទៅលើផ្លូវចិត្តរបស់ រង្ស៊ី ក្នុងឋានៈជាមនុស្ស និងពលរដ្ឋផង។ ដូច្នេះ វាក៏មិនមែនជាដំណោះស្រាយល្អ និង ស្ពាតសំរាប់របបនៅភ្នំពេញនោះដែរ។ អំពើហិង្សាគ្រប់រូបភាព ជាអកុសល មានបាបចេញមុខឱ្យផល៕

[1] ស្ថានការណ៍ : scénario.